**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានីភ្នំពេញ**
លេខ : ០០៦/២១ សរណន

# សេចក្តីណែនាំ

## ស្តីពី

## ការរឹតបន្តឹងការអនុវត្តវិធានការសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និងរបៀបរៀបរយ និង វិធានការបង្ការ-ទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ-១៩ នៅក្នុងឱកាសឈប់សម្រាក នៃពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ

**យោង៖** - សារាចរណែនាំលេខ ០១ សរណន ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការឈប់សម្រាកក្នុងពិធីបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ ពីថ្ងៃពុធ ៣កើត ខែពិសាខ ឆ្នាំឆ្លូវ ទោស័ក ព.ស.២៥៦៤ ដល់ថ្ងៃសុក្រ ៥កើត ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១៤ ដល់ថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២១ និង វិធានការបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ-១៩ នៅក្នុងឱកាសឈប់សម្រាកនេះ

- សារាចរណែនាំលេខ ០២ សរណន ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពី វិធានការបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ-១៩ នៅក្នុងឱកាសឈប់សម្រាកក្នុងពិធីបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ ពីថ្ងៃពុធ ៣កើត ខែពិសាខ ឆ្នាំឆ្លូវ ទោស័ក ព.ស.២៥៦៤ ដល់ថ្ងៃសុក្រ ៥កើត ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១៤ ដល់ថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២១
- សេចក្តីណែនាំ ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០២១ របស់ក្រសួងសុខាភិបាល ស្តីពីការការពារការចម្លងវីរុសកូវីដ-១៩ ក្នុងអំឡុងពិធីបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ
- សេចក្តីសម្រេចលេខ ០៦៨/២១ សសរ ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០២១ របស់រដ្ឋបាលរាជធានីភ្នំពេញ ស្តីពីការអនុវត្តវិធានការរដ្ឋបាលជាបណ្តោះអាសន្ន ដើម្បីទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ។

ក្នុងឱកាសឈប់សម្រាក នៃពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ គ.ស.២០២១ ពីថ្ងៃពុធ ៣កើត ខែពិសាខ ឆ្នាំឆ្លូវ ទោស័ក ព.ស.២៥៦៤ ដល់ថ្ងៃសុក្រ ៥កើត ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៤ **ត្រូវនឹងថ្ងៃទី១៤ ដល់ថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២១** ខាងមុខនេះ **និងស្របពេលដែល "ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ២០២១"** ក្នុងមូលដ្ឋានរាជធានីភ្នំពេញមិនទាន់មានភាពធូរស្រាលនៅឡើយនោះ **រដ្ឋបាលរាជធានីភ្នំពេញ** សូមធ្វើការណែនាំដល់បងប្អូនប្រជាពលរដ្ឋ យុវជន-យុវនារី កម្មករ-កម្មការិនី និងសាធារណជនទាំងអស់ **ត្រូវចូលរួមអនុវត្តវិធានការសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និងរបៀបរៀបរយ និង វិធានការបង្ការ-ទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ-១៩** ដូចខាងក្រោម៖



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

១. ត្រូវបង្កើនស្មារតីប្រុងប្រយ័ត្នខ្ពស់ចំពោះភ្លើងទៀន-ធូប ភ្លើងចង្ក្រាន ការប្រើប្រាស់ប្រេងឥន្ធនៈ-ឧស្ម័នហ្គាស និងចរន្តអគ្គិសនី ដើម្បីបង្ការ-ទប់ស្កាត់គ្រោះអគ្គិភ័យជាយថាហេតុ និងដើម្បីបញ្ចៀសការបាត់បង់ទ្រព្យសម្បត្តិ និងអាយុជីវិតប្រជាពលរដ្ឋទូទៅ។

២. ហាមដាច់ខាតការលេងល្បែងស៊ីសងគ្រប់ប្រភេទ និងការលេងបាញ់ទឹក ជះទឹក គប់ស្បោងទឹក ប៉ាតម្សៅលាបធ្យូង វាយដោយរំពាត់ ឬ ឧបករណ៍ផ្សេងៗ អុជផាវ និងគ្រឿងផ្ទុះផ្សេងៗ ដែលជាសកម្មភាពខុសច្បាប់ និងប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ប្រពៃណីដ៏ល្អផូរផង់របស់សង្គមជាតិ។

៣. ចៀសវាងការធ្វើដំណើរចេញក្រៅលំនៅឋាន ឬ ទីសំណាក់ដែលមិនចាំបាច់ និងចៀសវាងការធ្វើដំណើរកម្សាន្ត ឬ ធ្វើដំណើរទៅកាន់ខេត្តផ្សេងៗ **ដែលអាចជាហានិភ័យខ្ពស់នៃការចម្លងជំងឺកូវីដ-១៩ ទៅបុគ្គលដទៃ គ្រួសារផ្សេងទៀត និងក្នុងសហគមន៍កាន់តែធ្ងន់ធ្ងរ** ព្រោះថា **រាជធានីភ្នំពេញ** ត្រូវបានក្រសួងសុខាភិបាល កំណត់ថាជាទីតាំងភូមិសាស្ត្រក្នុងចំណោម **៥ រាជធានី-ខេត្ត** មានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ក្នុង **"ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ២០២១"**។

៤. ផ្អាកការរៀបចំសង្ក្រាន្ត **"ទន្លេដី"** និងការរៀបចំសង្ក្រាន្តតាមបណ្តាខណ្ឌទាំង ១៤ ក្នុងឱកាសនៃពិធីបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៤ គ.ស.២០២១ នាពេលខាងមុខនេះ។

៥. ហាមដាច់ខាតការប្រមូលផ្តុំរៀបចំកម្មវិធីកម្សាន្តបែបប្រពៃណី កម្មវិធីរាំច្រៀង ពិធីជប់លៀង និងការជួបជុំគ្រប់ប្រភេទ ដែលមានសភាពអ៊ូអរ និងមានមនុស្សចូលរួមច្រើន **លើកលែងតែការជួបជុំក្នុងចំណោមសមាជិកគ្រួសារដែលរស់នៅក្នុងលំនៅឋាន ឬ ទីសំណាក់ជាមួយគ្នា**។

៦. គ្រប់វត្តអារាម ទីកន្លែងសក្ការៈបូជា រមណីយដ្ឋាន ភោជនីយដ្ឋាន-អាហារដ្ឋាន អាជីវកម្មដ្ឋាន និងទីតាំងសប្បាយភាពនានា ត្រូវផ្តល់កិច្ចសហការល្អជាមួយអាជ្ញាធរមូលដ្ឋាន និងមន្ត្រីជំនាញមានសមត្ថកិច្ចក្នុងនោះ គណៈគ្រប់គ្រង ឬ ម្ចាស់ទីតាំង ត្រូវចាត់ចែងអនុវត្តដូចជា **(១)** ចាត់ឱ្យមានអ្នកវាស់កម្តៅ បាញ់អាល់កុល-ជែល ចែកម៉ាស និងចូលរួមអនុវត្តការស្កេន QR Code "ទប់ស្កាត់កូវីដ Stop Covid" **(២)** អនុវត្តកាតព្វកិច្ចពាក់ម៉ាស និងកាតព្វកិច្ចរក្សាគម្លាតសុវត្ថិភាពឱ្យបានត្រឹមត្រូវ **(៣)** រៀបចំទីតាំងឱ្យមានខ្យល់ចេញ-ចូលគ្រប់គ្រាន់ ចៀសវាងទីតាំងបិទជិត និងប្រើម៉ាស៊ីនត្រជាក់ច្រើនពេក **និង (៤)** កំណត់ចំនួនមនុស្សចេញ-ចូលជា**អតិបរមា** សមាមាត្រទៅនឹងទំហំទីតាំង **ចៀសវាងដាច់ខាតការប្រជ្រៀតគ្នា ឬ ប្រមូលផ្តុំមនុស្សច្រើន ខុសពីវិធានសុខាភិបាល**។

៧. ចំពោះក្រុមហ៊ុនដឹកជញ្ជូនអ្នកដំណើរគ្រប់ប្រភេទ ក្នុងមូលដ្ឋានរាជធានីភ្នំពេញ **មិនត្រូវដំឡើងថ្លៃសេវាដឹកជញ្ជូនអ្នកដំណើរឡើយ និងត្រូវយកចិត្តទុកដាក់អនុវត្តវិធានការសុខាភិបាល** សំដៅបង្ការ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ក្នុងចំណោមអ្នកបើកបរ-បុគ្គលិក និងអ្នកដំណើរទាំងឡាយដែលប្រើប្រាស់សេវាកម្មដឹកជញ្ជូនរបស់ក្រុមហ៊ុនខ្លួន។

៨. **សូមលើកទឹកចិត្តចំពោះការសម្រាកជួបជុំក្រុមគ្រួសារនៅក្នុងលំនៅឋានរៀងៗខ្លួន** ហើយប្រសិនបើមានតម្រូវការចាំបាច់ខានមិនបានក្នុងការធ្វើដំណើរ ត្រូវប្រកាន់ខ្ជាប់ជានិច្ចការគោរពច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន សមស្របតាមពាក្យស្លោកដែលដាក់ចេញដោយប្រមុខរាជរដ្ឋាភិបាលកម្ពុជា គឺ **"ថ្ងៃនេះ ថ្ងៃស្អែក គ្មានគ្រោះថ្នាក់ចរាចរណ៍"** និងត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់តាមការណែនាំ របស់ក្រសួងសុខាភិបាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ចូលទៅក្នុងសហគមន៍។



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

៩. ត្រូវបង្កើនស្មារតីយកចិត្តទុកដាក់អនុវត្តវិធានការការពារខ្លួន គ្រួសារ និងសហគមន៍ ស្របតាមរបត់ថ្មីគឺ **"ការរស់នៅធម្មតា តាមបែបគន្លងថ្មី ក្នុងបរិបទប្រយុទ្ធនឹងជំងឺកូវីដ-១៩"** តាមរយៈការប្រកាន់ខ្ជាប់នូវគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាល និងវិធានការ **"៣ ការពារ និង ៣ កុំ"** របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។**

**រដ្ឋបាលរាជធានីភ្នំពេញ** សូមបញ្ជាក់ជូនផងដែរថា ចំពោះវិធានការរដ្ឋបាលរួមមាន **(ទី១)** ការផ្អាកជាបណ្តោះអាសន្ននូវសកម្មភាពអាជីវកម្មចំពោះតូបអាហារ អាហារដ្ឋាន ភោជនីយដ្ឋាន ហាងកាហ្វេ ហាងភេសជ្ជៈ និងភោជនីយដ្ឋាននៅតាមសណ្ឋាគារ ។ល។ ដែលទទួលអតិថិជនចូលមកទទួលទានអាហារភេសជ្ជៈ ឬ ទទួលទានគ្រឿងស្រវឹង **(ទី២)** ការផ្អាកជាបណ្តោះអាសន្ននូវការប្រមូលផ្តុំ ឬការជួបជុំគ្នាទទួលទានអាហារ ភេសជ្ជៈ ឬ ទទួលទានគ្រឿងស្រវឹង **(និង ទី៣)** ការផ្អាកជាបណ្តោះអាសន្ននូវការធ្វើចរាចរណ៍ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ នៅចន្លោះម៉ោង ២០ (ម្ភៃ) ដល់ម៉ោង ៥ (ប្រាំ) **ត្រូវបន្តអនុវត្តជាប់ជាប្រចាំរហូតដល់អស់សុពលភាព** ស្របតាមខ្លឹមសារនៃសេចក្តីសម្រេចលេខ **០៦៨/២១ សសរ** ចុះ**ថ្ងៃទី១ ខែមេសា ឆ្នាំ២០២១** របស់រដ្ឋបាលរាជធានីភ្នំពេញ ស្តីពីការអនុវត្តវិធានការរដ្ឋបាលជាបណ្តោះអាសន្ន ដើម្បីទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ។

ទទួលបានសេចក្តីណែនាំនេះ នាយករដ្ឋបាលសាលារាជធានីភ្នំពេញ ស្នងការនគរបាលរាជធានីភ្នំពេញ មេបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញ អភិបាល នៃគណៈអភិបាលខណ្ឌទាំង១៤ ប្រធានមន្ទីរ-អង្គភាពជំនាញជុំវិញរដ្ឋបាលរាជធានីភ្នំពេញ ប្រជាពលរដ្ឋ យុវជន-យុវនារី កម្មករ-កម្មការិនី សាធារណជន និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ត្រូវចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះ ឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់៕

ថ្ងៃ ចន្ទ៨រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២១
**អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

**ឃួង ស្រេង**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងធម្មការ និងសាសនា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

  *"ដើម្បីជូនជ្រាបជាព័ត៌មាន"*
- ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ
- រដ្ឋបាលខណ្ឌទាំង១៤
- មន្ទីរ-អង្គភាពជំនាញជុំវិញរដ្ឋបាលរាជធានីភ្នំពេញ

  *"ដើម្បីមុខការ!"*
- គ្រប់ប្រព័ន្ធឃោសនា

  *"ដើម្បីផ្សព្វផ្សាយ"*
- ឯកសារ-កាលប្បវត្តិ



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh